# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈ
## របស់
# បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា

Cambodia Women Entrepreneurs' Network (CamWEN)

## ជំពូក១
## បេសកកម្ម និងគោលបំណង

**ប្រការ ១.-** **អំពីបេសកកម្ម**

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានបេសកកម្ម ពង្រឹង និងពង្រីកកាលានុវត្តភាព សម្រាប់ការអភិវឌ្ឍសហគ្រិនភាពស្ត្រីនៅកម្ពុជា ក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ តាមរយៈការលើកកម្ពស់បណ្តាញទំនាក់ទំនង ការផ្លាស់ប្តូរបទពិសោធន៍ ការប្រមូលផ្តុំសម្លេងដ៏រឹងមាំរបស់ស្ត្រីជាសហគ្រិន និងអាជីវករ ក៏ដូចជាក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធ សម្រាប់ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ។

**ប្រការ ២.-** **អំពីគោលបំណង**

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានគោលបំណងសំខាន់ៗ៖

- សម្របសម្រួល និងជំរុញការពង្រឹង និងពង្រីកបណ្តាញទំនាក់ទំនង ជួយគាំទ្រគ្នាទៅវិញទៅមក ចែករំលែកព័ត៌មាននិងមេរៀនបទពិសោធន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍសហគ្រិនភាពស្ត្រី ។
- ចូលរួមចំណែកក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យធុរៈកិច្ចនៅកម្ពុជា ក្នុងតំបន់ និងអន្តរជាតិ។
- លើកកម្ពស់ភាពចម្រុះ និងបរិយាប័ន្ន ក្នុងការឆ្លើយតបលើបញ្ហា និងតម្រូវការរបស់ស្ត្រី ក្នុងវិស័យធុរៈកិច្ច សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម ។
- ប្រមូលផ្តុំ និងលើកកម្ពស់ភាពជាតំណាងសម្លេងរបស់ស្ត្រីជាសហគ្រិន រួមទាំងសហគ្រិនស្ត្រីវ័យក្មេង ក្នុងវិស័យធុរៈកិច្ច នៅក្នុងកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល ជាមួយវិស័យឯកជន ។
- ពង្រឹងភាពជាតំណាងសហគ្រិនស្ត្រីនៅកម្ពុជា សម្រាប់ចូលរួមជាតំណាង ចែករំលែកបទពិសោធន៍ កិច្ចសហការ និងភ្ជាប់បណ្តាញទំនាក់ទំនងជាមួយបណ្តាញសហគ្រិនស្ត្រីអាស៊ាន (ASEAN

Women Entrepreneurs Network, AWEN) និងបណ្តាញសហគ្រិននានា ព្រមទាំងសហគមន៍ផ្សេងៗ ក្នុងតំបន់ និងលើឆាកអន្តរជាតិ ។

## ជំពូក២
## អំពីឈ្មោះ ទីស្នាក់ការ អត្តសញ្ញាណ សញ្ញាសម្គាល់ និងត្រា

### ប្រការ ៣.- អំពីឈ្មោះ

បណ្តាញនេះមានឈ្មោះជាភាសាខ្មែរថា **បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា** ដែលហៅកាត់ «**ប.ស.ស.ក**» និងមានឈ្មោះជាភាសាអង់គ្លេសថា Cambodia Women Entrepreneurs' Network ដែលហៅកាត់ «CamWEN»។

### ប្រការ ៤.- អំពីទីស្នាក់ការ

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានទីស្នាក់ការនៅរាជធានីភ្នំពេញ ឬអាចត្រូវផ្លាស់ប្តូរ ទៅតាមអាណត្តិរបស់ប្រធានបណ្តាញ។

### ប្រការ ៥.- អំពីអត្តសញ្ញាណ

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* គឺជាបណ្តាញជាតិ តំណាងឱ្យស្ត្រី សហគមន៍ សមាគម ឬសហព័ន្ធ នៅក្នុងវិស័យធុរៈកិច្ច សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម។

### ប្រការ ៦.- អំពីសញ្ញាសម្គាល់ និងត្រា

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានសញ្ញាសម្គាល់ និងត្រា តាមការពិភាក្សានិងអនុម័តដោយកិច្ចប្រជុំ របស់បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា និងត្រូវទទួលស្គាល់ជាផ្លូវការ ទៅតាមនីតិវិធី និងច្បាប់នៃព្រះរាជណាចក្រកម្ពុជា ។

ត្រារបស់បណ្តាញ ត្រូវចាត់ចែង និងទទួលខុសត្រូវ ដោយប្រធានបណ្តាញ ។

## ជំពូក៣
## អំពីសមាជិកភាព ការបាត់បង់សមាជិកភាព

### ប្រការ ៧.- អំពីសមាជិកភាព

បេក្ខភាពដែលអាចស្នើសុំជាសមាជិក*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* ត្រូវស្របតាមលក្ខខណ្ឌណាមួយ ក្នុងចំណោមលក្ខខណ្ឌ ដូចខាងក្រោម៖

- តំណាងឱ្យក្រុម សហព័ន្ធ ឬសមាគមស្ត្រី ក្នុងវិស័យធុរៈកិច្ច នៃសហគ្រាសខ្នាតមីក្រូ តូចនិងមធ្យម នៅកម្ពុជា ដែលមានសមាជិករបស់ខ្លួន យ៉ាងតិច២៥នាក់។
- តំណាងឱ្យក្រុម សហព័ន្ធ សហគមន៍ ឬសមាគមសហគ្រិន និងធុរៈកិច្ចនានានៅកម្ពុជា ដែលមានសមាជិកជាស្ត្រីយ៉ាងតិច ៥០នាក់ ។

តំណាងអង្គភាព ឬកម្មវិធី គំនិតផ្តួចផ្តើមថ្មីៗ ក្នុងការលើកកម្ពស់ការអភិវឌ្ឍសហគ្រិនភាពស្ត្រីនៅកម្ពុជា និង ទទួលស្គាល់ជាផ្លូវការ ដោយស្ថាប័នជាតិ។

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* ពិនិត្យ និងសម្រេចសំណើសមាជិកភាពថ្មីរបស់ខ្លួនស្របតាមលក្ខខណ្ឌណាមួយខាងលើ តាមរយៈកិច្ចប្រជុំពេញអង្គ ឬកិច្ចប្រជុំវិសាមញ្ញរបស់បណ្តាញដោយសម្លេងភាគច្រើន (៥០+១) ។

**ប្រការ ៨.** **អំពីភាពជាដៃគូ**

តំណាងអង្គភាព ឬកម្មវិធី គំនិតផ្តួចផ្តើមថ្មីៗ ក្នុងការលើកកម្ពស់ការអភិវឌ្ឍសហគ្រិនភាពស្ត្រីនៅកម្ពុជា ដែលទទួលស្គាល់ជាផ្លូវការ ដោយស្ថាប័នជាតិ គឺជាដៃគូសហប្រតិបត្តិការរបស់បណ្តាញ។

**ប្រការ ៩.** **អំពីការបាត់បង់សមាជិកភាព**

ចំពោះការបាត់បង់សមាជិកភាពរបស់បណ្តាញ ត្រូវកំណត់ក្នុងលក្ខខណ្ឌណាមួយ ដូចខាងក្រោម៖

- បានដាក់ពាក្យសុំលាឈប់មកបណ្តាញ ដោយផ្ទាល់ជាលាយលក្ខណ៍អក្សរ
- ដោយក្រុម សហព័ន្ធ សមាគម អង្គភាព បាត់បង់នីតិបុគ្គលរបស់ខ្លួន ឬលែងមានលក្ខណៈសម្បត្តិស្របតាមលក្ខខណ្ឌរបស់សមាជិកភាព ក្នុងប្រការ ៧
- ការសម្រេចរបស់កិច្ចប្រជុំពេញអង្គរបស់បណ្តាញ ដោយសម្លេងភាគច្រើន(៥០+១) ។

## ជំពូក៤
## រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

**ប្រការ ១០.- អំពីរចនាសម្ព័ន្ធ**

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានរចនាសម្ព័ន្ធគ្រប់គ្រង ដូចខាងក្រោម៖

- កិច្ចប្រជុំពេញអង្គប្រចាំឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញទៅតាមតម្រូវការ
- គណៈកម្មការប្រឹក្សាយោបល់
- ក្រុមប្រឹក្សាភិបាលបណ្តាញ។

**ប្រការ ១១.-  អំពីប្រជុំពេញអង្គប្រចាំឆ្នាំ**

កិច្ចប្រជុំពេញអង្គ ត្រូវរៀបចំយ៉ាងតិច ១ដង (មួយដង) ក្នុង១ឆ្នាំ (មួយឆ្នាំ) ក្រោមអធិបតីភាពរបស់ប្រធានគណៈកម្មការប្រឹក្សាយោបល់ និងដោយមានការចូលរួមពីសមាជិក សមាជិកាគណៈកម្មការប្រឹក្សាយោបល់ ក្រុមប្រឹក្សាភិបាល និងសមាជិករបស់បណ្តាញ ព្រមទាំងអ្នកពាក់ព័ន្ធតាមការចាំបាច់។

កិច្ចប្រជុំពេញអង្គ អាចមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- បោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលរបស់បណ្តាញ រៀងរាល់២ឆ្នាំម្តង
- ពិនិត្យវាយតម្លៃលើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុដែលអនុវត្តកន្លងមក
- ពិនិត្យ និងអនុម័តលើទិសដៅ និងគោលបំណងសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់
- ពិនិត្យ និងអនុម័តលើការធ្វើវិសោធនកម្មលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ពិនិត្យ និងអនុម័តលើសំណើសមាជិកភាពថ្មី
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗ ដែលស្នើឡើងដោយក្រុមប្រឹក្សាភិបាល។

ការចូលរួមជាអ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំ និងព្រឹត្តិការណ៍នានារបស់បណ្តាញ នៃតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល អ្នកសិក្សាស្រាវជ្រាវជាដើម អាស្រ័យតាមសំណើ និងការអញ្ជើញពីប្រធានបណ្តាញ ដោយមានការពិភាក្សា និងពិគ្រោះយោបល់ពីប្រធានគណកម្មការប្រឹក្សាយោបល់។

អ្នកសង្កេតការណ៍ក្នុងកិច្ចប្រជុំពុំមានសិទ្ធិបោះឆ្នោតនោះទេ។

**ប្រការ ១២.-  អំពីប្រជុំវិសាមញ្ញ**

កិច្ចប្រជុំវិសាមញ្ញអាចរៀបចំតាមតម្រូវការចាំបាច់ ដោយការស្នើសុំ និងអញ្ជើញរបស់ប្រធានបណ្តាញ និងដោយមានការសុំយោបល់ពីប្រធានគណៈកម្មការប្រឹក្សាយោបល់ ។

កិច្ចប្រជុំវិសាមញ្ញ អាចមានភារកិច្ចសំខាន់ៗ ដូចខាងក្រោម៖

- ពិនិត្យពិភាក្សាកែប្រែ និងអនុម័តលក្ខន្តិកៈក្នុងករណីចាំបាច់
- ពិនិត្យពិភាក្សានិងសម្រេចលើការបញ្ចូលសមាជិកថ្មី
- ពិនិត្យ និងដោះស្រាយការងារផ្សេងៗទៀតដែលស្នើឡើងដោយសមាជិករបស់បណ្តាញ ។

**ប្រការ ១៣.-  អំពីគណៈកម្មការប្រឹក្សាយោបល់**

គណៈកម្មការប្រឹក្សាយោបល់របស់បណ្តាញ មានតួនាទីក្នុងការលើកកម្ពស់ទស្សនៈវិស័យ និងគោលបំណងរបស់បណ្តាញ ក៏ដូចជាពង្រឹង និងពង្រីកកិច្ចសន្ទនារវាងរាជរដ្ឋាភិបាល ជាមួយវិស័យឯកជនលើការអភិវឌ្ឍសហគ្រិនភាពស្រ្តីនៅកម្ពុជា ។

គណៈកម្មការប្រឹក្សាយោបល់ នឹងដឹកនាំដោយរដ្ឋមន្រ្តីក្រសួងកិច្ចការនារី និងមានសមាជិកជាតំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចខាងក្រោម ៖

- ក្រសួងកិច្ចការនារី
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងទេសចរណ៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិ ជំរុញចលនា ភូមិ១ ផលិតផល១
- សភាពាណិជ្ជកម្មកម្ពុជា

តំណាងក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ដែលជាសមាជិក សមាជិកា**គណៈកម្មការប្រឹក្សាយោបល់** ដើរតួនាទី ក្នុងការផ្សារភ្ជាប់ និងឆ្លើយតបលើរបៀបវារៈការងារ និងបញ្ហានានា ជាមួយនឹងគោលនយោបាយ និងកម្មវិធីតាមវិស័យរបស់ខ្លួន និងផ្តល់ការណែនាំដល់បណ្តាញសហគ្រិនស្រ្តីនៅកម្ពុជា និងដៃគូពាក់ព័ន្ធ ដោយផ្សារភ្ជាប់តម្រូវការរបស់សហគ្រិនស្រ្តី ជាមួយនឹងក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្រ្ត និងកម្មវិធីជាតិ ព្រមទាំងផ្តល់ការតម្រង់ទិសលើការអភិវឌ្ឍសហគ្រិនភាពស្រ្តី រួមទាំងបញ្ហាផ្សេងៗទៀតដែលលើកឡើងដោយបណ្តាញ ។

ក្រសួងកិច្ចការនារី នឹងចាត់តាំងមន្រ្តីបច្ចេកទេសជាន់ខ្ពស់ ០១រូប ដែលមានភារកិច្ចជាអ្នកសម្របសម្រួលជាមួយបណ្តាញសហគ្រិនស្រ្តីនៅកម្ពុជា ដើម្បីគាំទ្របច្ចេកទេសដល់ថ្នាក់ដឹកនាំបណ្តាញ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងរវាងបណ្តាញសហគ្រិនស្រ្តីនៅកម្ពុជា ជាមួយស្ថាប័នរដ្ឋ ឯកជន និងដៃគូពាក់ព័ន្ធ ព្រមទាំងរាយការណ៍អំពីព័ត៌មានចាំបាច់នានាជូនប្រធានគណៈកម្មការប្រឹក្សាយោបល់ ។

**ប្រការ ១៤.- អំពីក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល ជាថ្នាក់ដឹកនាំរបស់បណ្តាញ ជ្រើសរើសតាមរយៈកិច្ចប្រជុំពេញអង្គ ដែលមានអាណត្តិ ២ឆ្នាំ (ពីរឆ្នាំ) និងមានសមាសភាព យ៉ាងតិច ចំនួន ៥រូប។

ប្រធានក្រុមប្រឹក្សាភិបាល ត្រូវជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយសម្លេងភាគច្រើន (៥០+១) ក្នុងកិច្ចប្រជុំពេញអង្គរបស់បណ្តាញ ដែលសមាជិករបស់បណ្តាញជាអង្គបោះឆ្នោត។

ស្របតាមអាណត្តិនីមួយៗ នៃការជ្រើសរើសប្រធានក្រុមប្រឹក្សាភិបាល ក្នុងករណីដែលសម្លេង ឬលទ្ធផលនៃការបោះឆ្នោត មិនអាចសម្រេចសមាសភាពប្រធាន នោះប្រធានគណកម្មការប្រឹក្សាយោបល់ តាមរយៈការពិគ្រោះយោបល់ជាមួយសមាជិកនានារបស់គណកម្មការប្រឹក្សាយោបល់ អាចសម្រេចចាត់តាំងសមាសភាពប្រធានក្រុមប្រឹក្សាភិបាល ។

ប្រធានក្រុមប្រឹក្សាភិបាល ដែលជាប្រធានបណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា មានតួនាទីជាតំណាងជាតិនៃបណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា ឱ្យស្របតាមក្របខ័ណ្ឌគោលនយោបាយ និងកម្មវិធីជាតិ ក្រោមការណែនាំរបស់ប្រធានគណកម្មការប្រឹក្សាយោបល់។

ប្រធាន ឬតំណាង ជាតំណាងបណ្តាញសហគ្រិនស្ត្រីកម្រិតជាតិ នៅក្នុងបណ្តាញសហគ្រិនស្ត្រីអាស៊ាន (AWEN) និងបណ្តាញ ឬអង្គការនានា ក្នុងប្រទេស តំបន់ និងអន្តរជាតិ។

ប្រធានជាតំណាងឱ្យបណ្តាញ និងមានតួនាទីជាអ្នកដឹកនាំ និងទទួលខុសត្រូវលើការងារប្រតិបត្តិការប្រចាំថ្ងៃ និងប្រតិបត្តិការជាមួយសមាជិកដទៃទៀត។

ប្រធាន ត្រូវសម្របសម្រួល និងកៀរគរ ដើម្បីស្វែងលទ្ធភាព និងមធ្យោបាយសមស្រប ក្នុងការគាំទ្រដល់តម្រូវការនានារបស់បណ្តាញ រួមទាំង លើការងាររដ្ឋបាល និងហិរញ្ញវត្ថុចាំបាច់របស់បណ្តាញ ។

ប្រធាន អាចរៀបចំ និងចាត់តាំងក្រុមការងារ ឬក្រុមលេខាធិការដ្ឋាន ដើម្បីជាជំនួយការ ក្នុងការសម្របសម្រួលសកម្មភាព ទំនាក់ទំនង និងចែករំលែកព័ត៌មានជាប្រចាំ ក្នុងចំណោមសមាជិក និងរក្សាទុករាល់ឯកសាររបស់បណ្តាញ។

កិច្ចការសំខាន់ៗរបស់ក្រុមការងារ ឬក្រុមលេខាធិការដ្ឋានរបស់បណ្តាញ រួមមាន៖

- សម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់បណ្តាញ ស្របតាមការណែនាំ និងផ្តល់សិទ្ធិដោយប្រធាន
- គាំទ្រក្នុងការធ្វើឱ្យប្រសើរនូវទំនាក់ទំនងរវាងប្រធាន ជាមួយនឹងសមាជិក សមាជិកាគណៈកម្មការប្រឹក្សាយោបល់ អ្នកសម្របសម្រួលដែលជាមន្ត្រីជាន់ខ្ពស់ក្រសួងកិច្ចការនារី សមាជិកបណ្តាញ និងស្ថាប័ន ដៃគូពាក់ព័ន្ធ
- ជួយគាំទ្រដល់កិច្ចការត្រៀមរៀបចំកិច្ចប្រជុំនានារបស់បណ្តាញ
- សហការសម្របសម្រួលជាមួយសមាជិកបណ្តាញ និងអ្នកពាក់ព័ន្ធ តាមការចាំបាច់ ដើម្បីរៀបចំផែនការសកម្មភាពរយៈពេលមធ្យម (៣-៥ឆ្នាំ) ផែនការសកម្មភាព និងគ្រោងថវិកាប្រចាំឆ្នាំ ធ្វើរបាយការណ៍វឌ្ឍនភាព និងកិច្ចការនានា តាមការកំណត់របស់ប្រធាន
- រៀបចំរបាយការណ៍ប្រចាំឆ្នាំជូនប្រធាន និងដើម្បីដាក់ជូនប្រធានគណៈកម្មការប្រឹក្សាយោបល់
- សម្របសម្រួលការទំនាក់ទំនង និងចែកចាយព័ត៌មានលើកិច្ចសហប្រតិបត្តិការរបស់ ***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** ជាមួយបណ្តាញ ឬអង្គការនានា ក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ

- ទទួល និងរៀបចំឯកសារពាក់ព័ន្ធលើពាក្យស្នើសុំចូលជាសមាជិកភាពថ្មី ដើម្បីដាក់ជូនអង្គប្រជុំពិនិត្យ និងសម្រេច
- បំពេញការងារផ្សេងៗតាមការកំណត់របស់ប្រធាន
- ក្រុមការងារ ឬក្រុមលេខាធិការដ្ឋានចាស់ ត្រូវជួយសម្របសម្រួល និងណែនាំដល់ក្រុមការងារ ឬក្រុមលេខាធិការថ្មី សម្រាប់អាណត្តិថ្មីរយៈពេលពី៣-៦ខែ ទៅតាមការស្នើសុំពីប្រធានបណ្តាញអាណត្តិថ្មី។

## ជំពូកទី៥
## វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬវិសោធនកម្មលក្ខន្តិកៈ

**ប្រការ ១៥.-** **អំពីវិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់**

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* អាចប្តូរឈ្មោះ ឬប្តូរសញ្ញាសម្គាល់បាន តាមសំណើសុំរបស់កិច្ចប្រជុំពេញអង្គប្រចាំឆ្នាំដោយសម្លេង៥០+១ ។

**ប្រការ ១៦.-** **អំពីការធ្វើវិសោធនកម្មលក្ខន្តិកៈ**

លក្ខន្តិកៈរបស់***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** អាចធ្វើវិសោធនកម្មបានតាមសំណើសុំរបស់ប្រធាន ឬតាមសំណូមពរ២/៣ (ពីរភាគបី) នៃសមាជិករបស់បណ្តាញ។

ការអនុម័តលើការសម្រេច នៃការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់បណ្តាញ គឺជាសមត្ថកិច្ចរបស់កិច្ចប្រជុំពេញអង្គរបស់បណ្តាញ ដោយសម្លេងភាគច្រើន២/៣ (ពីរភាគបី) ។

## ជំពូកទី៦
## ប្រភពធនធាន ទ្រព្យសម្បត្តិ និងការគ្រប់គ្រង

**ប្រការ ១៧.-** **អំពីប្រភពធនធាន ទ្រព្យសម្បត្តិ**

*បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា* មានប្រភពធនធាន តាមរយៈការខិតខំគៀរគរធនធាននៃគណៈកម្មការប្រឹក្សាយោបល់ ក្រុមប្រឹក្សាភិបាល និងសមាជិករបស់បណ្តាញ ពីប្រភពនានា សម្រាប់គាំទ្រដល់ដំណើរការ និងតម្រូវការចាំបាច់នានា របស់បណ្តាញ ។

**ប្រការ ១៨.-** **អំពីការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ**

មូលនិធិរបស់ ***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** ត្រូវគ្រប់គ្រង និងចាត់ចែងដោយប្រធានក្រុមប្រឹក្សាភិបាល។

## **ជំពូកទី៧**
## **អវសានប្បញ្ញត្តិ**

**ប្រការ ១៩.-**

រាល់បទបញ្ញត្តិទាំងឡាយណារបស់ ***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** ដែលមានខ្លឹមសារផ្ទុយពីលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២០.-**

រាល់ការធ្វើសកម្មភាព ***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** ត្រូវអនុវត្តន៍តាមលក្ខន្តិកៈដូចដែលបានឯកភាព និងអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់បណ្តាញ។

**ប្រការ ២១.**

លក្ខន្តិកៈរបស់ ***បណ្តាញសហគ្រិនស្ត្រីនៅកម្ពុជា*** មានសុពលភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាភិបាល**

**ប្រធាន**